**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ**

# ការវិភាគរបស់នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃលើការគណនា ថ្លៃលក់អគ្គិសនីសំរាប់តំបន់ចែកចាយថ្មី របស់អគ្គិសនីកម្ពុជា នៅទីរួមខេត្តកំពង់ស្ពឺ

## ១-សេចក្តីផ្តើម

អាជ្ញាធរអគ្គិសនីកម្ពុជាបានទទួលលិខិតរបស់អគ្គិសនីកម្ពុជាលេខ៣៩៨៣លស-អក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០០៤ ។ បន្ទាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាបានពិនិត្យសំណុំឯកសារស្នើសុំកំណត់ថ្លៃលក់អគ្គិសនីនៅទីរួមខេត្តចំនួន៨ ដែលជាតំបន់ធ្វើសេវាកម្មថ្មីរបស់អគ្គិសនីកម្ពុជាមកឃើញថា ពត៌មានដែលអគ្គិសនីកម្ពុជាបានផ្តល់ឱ្យអាជ្ញាធរមានចំណុចមួយចំនួនពុំទាន់ច្បាស់លាស់ដែលអាចឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការវាយតម្លៃបាននៅឡើយ ។ ដើម្បីឱ្យការពិនិត្យនិងវាយតម្លៃ អាចដំណើរការបានឆាប់ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៤ អាជ្ញាធរអគ្គិសនីកម្ពុជាបានផ្ញើលិខិតទៅអគ្គិសនីកម្ពុជាស្នើផ្តល់ឯកសារបន្ថែម និងចាត់មន្ត្រីជំនាញមកពិភាក្សាគ្នានៅស្នាក់ការអាជ្ញាធរអគ្គិសនីកម្ពុជា ។ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៥ អាជ្ញាធរអគ្គិសនីកម្ពុជានិងអគ្គិសនីកម្ពុជាបានបើកការប្រជុំពិភាក្សាស្តីពីការកំណត់ថ្លៃលក់អគ្គិសនីទាំង ៨ ខេត្ត ។ បន្ទាប់មកអគ្គិសនីកម្ពុជាបានរៀបចំឡើងវិញនិងស្នើសុំកំណត់ថ្លៃលក់អគ្គិសនីទាំង ៨ ខេត្ត ជាថ្មី តាមលិខិតលេខ៦០២លស-អក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥ ។ ពត៌មាន ដែលអគ្គិសនីកម្ពុជាបានផ្តល់ឱ្យអាជ្ញាធរជាលើកទី២នេះ មានលក្ខណៈគ្រប់គ្រាន់និងសមស្របសំរាប់ឱ្យអាជ្ញាធរអគ្គិសនីកម្ពុជាធ្វើការសិក្សានិងវាយតម្លៃបាន ។ ដូច្នេះ នាយកដ្ឋានហិរញ្ញវត្ថុ និងតម្លៃ នៃអាជ្ញាធរអគ្គិសនីកម្ពុជា សូមធ្វើការវិភាគលើការគណនាថ្លៃលក់អគ្គិសនីនៅទីរួមខេត្តកំពង់ស្ពឺ ដូចតទៅ:

## ២-ការវិភាគ

គំរោងរៀបចំបច្ចុប្បន្នក្នុងក្របខ័ណ្ឌឥណទានរបស់ ADB គឺការភ្ជាប់ទីរួមខេត្តកំពង់ស្ពឺជាមួយប្រព័ន្ធអគ្គិសនីរាជធានីភ្នំពេញ ។ ដូច្នេះ អ្នកប្រើប្រាស់នៅទីរួមខេត្តកំពង់ស្ពឺដែលនឹងបន្តភ្ជាប់ការប្រើប្រាស់ពីបណ្តាញរបស់អគ្គិសនីកម្ពុជា ក៏ដូចជាអ្នកប្រើប្រាស់នៅភ្នំពេញដែរ ។ អាជ្ញាធរអគ្គិសនីកម្ពុជាមានគោលនយោបាយរក្សាថ្លៃលក់អគ្គិសនីសំរាប់អ្នកប្រើប្រាស់នៅលើប្រព័ន្ធតែមួយឱ្យមានកំរិតដូចគ្នា ដោយមិនគិតការឧបត្ថម្ភ ។

### ៣-ការវាយតម្លៃរបស់នាយកដ្ឋានជំនាញ

អគ្គិសនីកម្ពុជាបានស្នើសុំលក់អគ្គិសនី **៦៥០រៀល**/kWh សំរាប់អ្នកប្រើប្រាស់ទូទៅក្នុងតំបន់ចែកចាយអគ្គិសនីនៅទីរួមខេត្តកំពង់ស្ពឺ ។ ដោយយល់ឃើញថាប្រព័ន្ធចែកចាយអគ្គិសនីនៅទីរួមខេត្តកំពង់ស្ពឺនេះនឹងក្លាយជាប្រព័ន្ធជាប់គ្នាតែមួយជាមួយប្រព័ន្ធអគ្គិសនីនៅភ្នំពេញ ដូច្នេះអាជ្ញាធរអគ្គិសនីកម្ពុជាពុំធ្វើការគណនាថ្លៃដើមទេក្នុងដំណាក់កាលអន្តរកាលនេះទេ ថ្លៃលក់អគ្គិសនីនៅទីរួមខេត្តកំពង់ស្ពឺ នឹងត្រូវកំណត់ដូចគ្នាជាមួយថ្លៃលក់អគ្គិសនីនៅរាជធានីភ្នំពេញ ដោយមិនត្រូវគិតការឧបត្ថម្ភធនឬការបំពេញខាតរបស់រាជរដ្ឋាភិបាលដែលផ្តល់ឱ្យសំរាប់តែរាជធានីភ្នំពេញ និងខេត្តកណ្តាលឡើយ ។

ដូច្នេះ នាយកដ្ឋានជំនាញយល់ថា អាជ្ញាធរអគ្គិសនីកម្ពុជាគួរអនុញ្ញាត និងឯកភាពឱ្យអគ្គិសនីកម្ពុជាលក់អគ្គិសនីឱ្យអ្នកប្រើប្រាស់ទូទៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជានៅទីរួមខេត្តកំពង់ស្ពឺ តាមអត្រា**៦៥០ រៀលក្នុង១គីឡូវ៉ាត់ម៉ោង** តាមសំណើសុំរបស់អគ្គិសនីកម្ពុជា ជាបណ្តោះអាសន្ន ។ ប៉ុន្តែ នៅពេលដែលថ្លៃលក់អគ្គិសនីនៅរាជធានីភ្នំពេញប្រែប្រួល នោះអាជ្ញាធរអគ្គិសនីកម្ពុជានឹងពិនិត្យមើលថ្លៃលក់អគ្គិសនីនៅទីរួមខេត្តកំពង់ស្ពឺឡើងវិញ ។

ភ្នំពេញ, ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៥

**ប្រធាននាយកដ្ឋាន**